Massachusetts Medical Orders for Life-Sustaining Treatment

# ចំឡើយចំពោះសំណួរដែលបានសួរញឹកញាប់
# សំរាប់អ្នកជំងឺ គ្រួសារ និងអ្នកថែទាំ

## *តើ “បទបញ្ជាពេទ្យ សំរាប់ការព្យាបាលទ្រទ្រង់ជីវិត” ជាអ្វី?*



ជាសេចក្តីណែនាំជាលាយលក្ខណ៍អក្សរ អំពីការខ្លះនៃការព្យាបាលសុខភាពទ្រទ្រង់ជីវិត *ចេញពី* វេជ្ជបណ្ឌិត ពេទ្យអនុវេជ្ជបណ្ឌិត ឬអនុការីវេជ្ជបណ្ឌិត ដើម្បី*ប្រាប់ណែនាំពីការព្យាបាល* ទៅអ្នកវិជ្ជាជីវៈថែសុខភាពផ្សេងទៀត (ដូចជាពេទ្យ អ្នកឆ្លើយតបអាសន្ន) ដោយយោងទៅលើចំណង់របស់អ្នកជំងឺ។ ក្រដាសបំពេញ បទបញ្ជាពេទ្យសំរាប់ការព្យាបាលទ្រទ្រង់ជីវិត (Medical Orders for Life-Sustainig Treatment, MOLST) គឺជាឯកសារពេទ្យ ស្របដៀងគ្នានឹងវេជ្ជបញ្ជា។

## *តើ “ការព្យាបាលទ្រទ្រង់ជីវិត” ជាអ្វី?*

ការព្យាបាលសុខភាព ដែលប៉ុនប៉ងរក្សាជីវិតមនុស្សឲ្យរស់រាន។ ការផ្ដុំដង្ហើមឲ្យបេះដូងដើរវិញ គឺជាឧទាហរណ៍មួយ។ អ្នកវិជ្ជាជីវៈថែសុខភាព គឺបានតម្រូវឲ្យប៉ុនប៉ងធ្វើ CPR នៅពេលបេះដូង ឬដង្ហើមរបស់អ្នកជំងឺឈប់ដើរ លុះត្រាតែគេមានបទបញ្ជាពេទ្យ (ដូចជាក្រដាសបំពេញ MOLST) ជាមួយសេចក្តីណែនាំផ្សេងៗទៀត។

## *តើជាជនអ្វីដែលចង់បំពេញ ក្រដាសទំរង់ MOLST ជាមួយនិងវេជ្ជបណ្ឌិតរបស់ពួកគេ ?*

អ្នកមានអាយុប៉ុន្មានក៏ដោយ (រួមទាំងក្មេងៗ) ដែលមានជំងឺធ្ងន់ធ្ងរទៅខាងមុខ ឬមានសុខភាពថមថយ ដែលប្រាថ្នាចង់មានឯកសាររបស់គេ អំពីការសំរេចចិត្តព្យាបាលសុខភាពទ្រទ្រង់ជីវិត។

## *តើអ្នកណាអាចបំពេញ ក្រដាសបំពេញ MOLST?*

អ្នកដែលមានជំងឺជំលឿន (ឬភ្នាក់ងារថែទាំសុខភាពរបស់គេ បើមនុស្សនោះខ្វះសមត្ថភាព) និងវេជ្ជបណ្ឌិត ពេទ្យអនុវេជ្ជបណ្ឌិត ឬអនុការី វេជ្ជបណ្ឌិត។ បើមិនបានតែងតាំងភ្នាក់ងារថែទាំសុខភាពទេ អាណាព្យាបាល ឬមាតាបិតា/អាណាព្យាបាលនៃអនីតិជន អាចបំពេញក្រដាសបំពេញ MOLST ទៅតាមវិសាលភាពដែលច្បាប់រដ្ឋម៉ាស្សាជូសេត្តបានអនុញ្ញាត *(ស្វែងរកជំនួយពីស្មាក្តីច្បាប់អំពីសំណួរនៃអាជ្ញារបស់អាណាព្យាបាល)*។

## *តើបំពេញក្រដាសទំរង់ MOLST នៅពេលណាទើបល្អ?*

វាអាចនឹងនៅពេលដែល :

- វាសមរម្យតាមលក្ខណៈសុខភាព ដោយយោងទៅលើលក្ខណៈសុខភាព*បច្ចុប្បន្ន* របស់គេ, *និង*
- គេ*ចង់* ប្រើក្រដាសបំពេញ MOLST, *និង*
- គេ (និងជាការល្អសំរាប់ ភ្នាក់ងារថែទាំសុខភាព និងមនុស្សជាទីស្រឡាញ់របស់បុគ្គល) បានពិភាក្សាគ្នាជាមួយនឹងវេជ្ជបណ្ឌិតរបស់គេ អំពីជំងឺ ការប៉ាន់ប្រមាណ តម្លៃនិងគោលដៅនៃការថែទាំរបស់គេ ផលប្រយោជន៍ដែលអាចមាន ព្រមទាំងបន្ទុកនៃការព្យាបាល។

## *តើគេនឹងបានតម្រូវឲ្យប្រើ ក្រដាសទំរង់ MOLST ឬទេ?*

ទេ។ ការប្រើក្រដាសបំពេញ MOLST គឺជាការស្ម័គ្រចិត្ត។

## *តើគេអាចដូរចិត្តរបស់គេ អំពីការព្យាបាល បន្ទាប់ពីគេបានបំពេញក្រដាសបំពេញ MOLST ឬទេ?*

អាច។ គេអាចស្នើសុំ និងទទួលការព្យាបាលដែលត្រូវការនៅពេលណាក៏បាន ទោះបើក្រដាសបំពេញ MOLST ថ្លែងយ៉ាងណាក៏ដោយ។ គេក៏អាចធ្វើឲ្យក្រដាសបំពេញ MOLST ជាមោឃៈ និង/ឬ សូមឲ្យវេជ្ជបណ្ឌិត ពេទ្យអនុវេជ្ជបណ្ឌិត ឬអនុការីវេជ្ជបណ្ឌិត បំពេញក្រដាសបំពេញមួយថ្មី ដោយមានសេចក្តីណែនាំផ្សេងទៀត នៅពេលណាក៏បាន។

**សំរាប់ព័ត៌មាន និងធនធានបន្ថែម សូមមើល** **www.molst-ma.org**

### *តើអ្នកណាត្រូវធ្វើតាមសេចក្តីណែនាំរបស់ MOLST?*

អ្នកវិជ្ជាជីវៈថែទាំសុខភាពមានអាជ្ញាប័ណ្ណ (ពេទ្យ អ្នកឆ្លើយតបអាសន្ន ជាដើម) ត្រូវគោរពបទបញ្ជាពេទ្យដែលយកជាការបាន រួមទាំង MOLST។

### *តើ MOLST ដូចគ្នានឹង “ អ្នកជំនួសការថែទាំសុខភាព អ្នកជំងឺ” ឬទេ?*

ទេ។ ក្រដាសបំពេញ *ជំនួសការថែទាំសុខភាព (health care proxy)* គឺជាក្រដាសបំពេញស្របច្បាប់ ដែលបានប្រើសំរាប់តែងតាំងភ្នាក់ងារថែទាំសុខភាពរបស់មនុស្ស - មានតែមនុស្សបានអនុញ្ញាតស្របច្បាប់ ដើម្បីធ្វើការសំរេចអំពីសុខភាពសំរាប់គេនៅពេលអនាគត បើគេមិនអាចធ្វើការសំរេចអំពីសុខភាពបាន (ដូចជា ពីព្រោះតែការបាត់បង់ស្មារតី, សន្លប់, ភាន់ស្មារតី ឬមានកំរិតខាងផ្លូវចិត្តផ្សេងទៀត)។ មនុស្សពេញវ័យអាយុ 18 ឆ្នាំ និងចាស់ជាង*គ្រប់ៗរូប* នៅក្នុងរដ្ឋម៉ាស្សាជូសេត្ត គួរតែបំពេញ និងចុះហត្ថលេខាក្រដាសបំពេញ ជំនួសការថែទាំសុខភាព។

### *បើសិនគេបានសរសេរ “សេចក្តីប្រាថ្នាចុងក្រោយ” ឬ “អវសានសាសន៍” តើមិនគ្រប់គ្រាន់ ឬទេ?*

ទាំងនោះគឺជាទំរង់នៃឯកសារ ដែលអាចនឹងបានប្រើជាភស្តុតាងនៃសេចក្តីប្រាថ្នារបស់គេ ប៉ុន្តែវាមិនបានអនុញ្ញាតដោយច្បាប់ នៅក្នុងរដ្ឋម៉ាស្សាជូសេត្តឡើយ។ វាពុំមានអាជ្ញាដូចគ្នានឹង*បទបញ្ជាពេទ្យ* ដូចជា MOLST ឡើយ។ បទបញ្ជាពេទ្យដែលប្រើការបាន ត្រូវបានគោរពដោយអ្នកផ្តល់ការថែទាំសុខភាព ក្នុងគ្រប់ទីកន្លែងទាំងអស់។

### *បើសិនគេមានបទបញ្ជា “កុំផ្ចុំដង្ហើមឲ្យដើរវិញ” (DNR) រួចហើយ តើគេនៅតែអាចប្រើក្រដាសបំពេញ MOLST ឬទេ?*

អាច។ ក្រដាសបំពេញ MOLST រួមមាននូវសេចក្តីណែនាំអំពីការផ្ចុំដង្ហើមឲ្យដើរវិញ និងការព្យាបាលទ្រទ្រង់ជីវិតផ្សេងទៀត។ ហើយវាមិនដូចនឹងគ្នាបទបញ្ជា DNR ទេ ត្បិតក្រដាសបំពេញ MOLST អាចបានប្រើដើម្បីបដិសេធ ឬ *ស្នើសុំ* ការព្យាបាល។

### *តើអ្នកណារក្សាទុកក្រដាសបំពេញ MOLST ដែលបានចុះហត្ថលេខា?*

គេ រក្សាទុកក្រដាសទំរង់ MOLST ជាមួយនិងគេ ក្នុងកន្លែងមួយដែលងាយរកឃើញ (លើទូទឹកកក, ក្បែរគ្រែ, ឬលើទ្វារ) និងយកវាទៅជាប់ខ្លួនគេនៅពេលធ្វើដំណើរទៅក្រៅពីផ្ទះ។ សំណៅក៏ប្រើការបានដែរ ហើយក៏អាចបានឲ្យទៅភ្នាក់ងារថែទាំសុខភាព និង/ឬ សមាជិកគ្រួសារ។

### *តើក្រដាសបំពេញ MOLST នឹងត្រូវបានគោរពនៅក្រៅរដ្ឋម៉ាស្សាជូសេត្ត ឬទេ?*

វាអាចនឹងត្រូវបានគោរពនៅក្នុងរដ្ឋមួយចំនួន ប៉ុន្តែមិននៅតាមរដ្ឋខ្លះទេ។ តែជាយ៉ាងណាមិញ ក្រដាសបំពេញ MOLST គឺតែងតែជាកំណត់ត្រាដ៏ល្អនៃចំណង់ការព្យាបាលរបស់គេ។